**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**SOCIAL PROTECTION IN CAMBODIA**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៨១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៤៩៦នាក់ នៃសហគ្រាសទាំង៣៣ នៃវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលសហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅសហគ្រាសទាំង៣៣ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលសហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករសហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៣រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០២២

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២**

**បញ្ជីឈ្មោះ សហគ្រាស ក្នុងវិស័យទេសចរណ៍**
**ចំនួន ៣៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| វិស័យទេសចរណ៍ | | 33 |
| 1 | ក្រុមហ៊ុន អេខ្ញើអេកស្តីឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 3 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 4 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 5 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 6 | ក្រុមហ៊ុន GB II Co., LTD | សៀមរាប |
| 7 | សណ្ឋាគារ អង្គរ | សៀមរាប |
| 8 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 9 | សណ្ឋាគារដឺឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 10 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 11 | សណ្ឋាគារ វីចេនស៊ីអង្គរ | សៀមរាប |
| 12 | ក្រុមហ៊ុន ម៉េម៉័រអង្គរ (ខេមបូឌា) | សៀមរាប |
| 13 | សណ្ឋាគារម៉េម៉័រសៀមរាប | សៀមរាប |
| 14 | អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 15 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ិនធើណេសិនណលត្រាវែល ស៊ីវីស | សៀមរាប |
| 16 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា(ភោជនីយដ្ឋានទន្លេមេគង្គ) | សៀមរាប |
| 17 | សណ្ឋាគារ ស្នាយលីង | សៀមរាប |

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 18 | សណ្ឋាគារគូលែន | សៀមរាប |
| 19 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 20 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 21 | ក្រុមហ៊ុន អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 22 | ក្រុមហ៊ុន អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 23 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 24 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 25 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 26 | ក្រុមហ៊ុន សាលាឡូជ | សៀមរាប |
| 27 | សណ្ឋាគារ អូរៀនថល ជេ7 | សៀមរាប |
| 28 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា(ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 29 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 30 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 31 | ក្រុមហ៊ុន ខមហ្វតប្រជឹធី ស៊ីលូសិន (ខូអិល ធីឌី) | សៀមរាប |
| 32 | ក្រុមហ៊ុន បា ឡឺ កូដ ត្រេឌីង | សៀមរាប |
| 33 | ក្រុមហ៊ុន អេប៊ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |